ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:.......០០៥/១១...គ.ម.ក ប្រ.ក.

# ប្រកាស

## ស្ដីពី

## ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ

* * * * *

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គមក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការផ្ដល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

- បានឃើញប្រកាសលេខ ០០៤ គមក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្ដីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញសំណើសុំការពិនិត្យ និងអនុម័ត លើវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១១

# ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិកនិងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី **០៣** ខែ **ឧសភា** ឆ្នាំ២០១១

**គាត ឈន់**

**កន្លែងទទួល ÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ ...០០៥/១១ គ.ម.ក.ប្រ.ក

ចុះថ្ងៃទី០៣ខែតុលាឆ្នាំ ២០១១

# វិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

*****

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

គោលបំណងនៃវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ នេះគឺដើម្បីកំណត់នូវគោលការណ៍នានាដែលចាំបាច់សម្រាប់ការផាត់ទាត់និងទូទាត់មូលបត្រ នៅក្នុងប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូល-បត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ដែលទទួលបានការអនុញ្ញាតស្របតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់-ព័ន្ធជាធរមាន។

-**សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ដោយមានសិទ្ធិប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្ររបស់ **ផ.ម.ក.**។

-**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនៃសេវារបស់ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្ររបស់ **ផ.ម.ក.**។

-**ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ** សំដៅដល់ធនាគារពាណិជ្ជដែលបានការទទួលស្គាល់ពី **គ.ម.ក.** ដូចមានចែងក្នុងប្រកាសស្តីពីការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ៣.- ប្រតិបត្តិការផាត់ទាត់និងទូទាត់**

ការជួញដូរមូលបត្រចុះបញ្ជី ត្រូវតែប្រតិបត្តិតាមការទូទាត់ធម្មតា។ ការទូទាត់ធម្មតា គឺជាការទូទាត់ដែលត្រូវធ្វើឡើងពីរថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+2)។

## ជំពូកទី ២

## ការទូទាត់រវាងប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសមាជិក

**ប្រការ ៤.- ភាតព្វកិច្ចទូទាត់របស់សមាជិក**

សមាជិកនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវធ្វើការទូទាត់លើប្រតិបត្តិការដែលបានជួញដូរ ឱ្យបាននៅកាលបរិច្ឆេទទូទាត់។

សមាជិកនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ មិនអាចប្រគល់ភារកិច្ចទូទាត់ប្រតិបត្តិការរបស់ខ្លួនទៅឱ្យសមាជិកដទៃទៀតឡើយ។

**ប្រការ ៥.- កាលបរិច្ឆេទផាត់ទាត់និងទូទាត់រវាងសមាជិក**

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ **គ.ម.ក.** ការទូទាត់ត្រូវធ្វើឡើងពីរថ្ងៃនៃថ្ងៃជួញដូរបន្ទាប់ពីថ្ងៃដែលមូលបត្រនោះត្រូវបានជួញដូរ (T+2)។ ថ្ងៃបិទទីផ្សារមិនត្រូវបានរាប់បញ្ចូលក្នុងចំនួនថ្ងៃអាជីវកម្មទេ។

**ប្រការ ៦.- ការជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

សមាជិកត្រូវជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** សម្រាប់បំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

**ប្រការ ៧.- ការបើកគណនីទូទាត់សម្រាប់ការទូទាត់សាច់ប្រាក់**

សមាជិកនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវបើកគណនីសាច់ប្រាក់ក្នុងនាមខ្លួនផ្ទាល់ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដូចមានចែងក្នុងប្រការ ៦ នៃវិធាននេះ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

បន្ទាប់ពីបានបើកគណនីសាច់ប្រាក់ ឬមានការផ្លាស់ប្តូរគណនីសាច់ប្រាក់ សមាជិកត្រូវរាយការណ៍អំពីឈ្មោះនៃភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួននិងលេខគណនីជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ យ៉ាងហោចណាស់ ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ មុនថ្ងៃចាប់ផ្តើមការជួញដូរ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវបើកគណនីទូទាត់សាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់សមាជិក ទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្ទេរសាច់ប្រាក់ដែលទទួលបាននេះ ទៅសមាជិកដែលត្រូវទទួលបានការទូទាត់សាច់-ប្រាក់។

## ប្រការ ៨.- ការបើកគណនីមូលបត្រសម្រាប់ការទូទាត់មូលបត្រ

សមាជិកត្រូវបើកគណនីមូលបត្រ ស្របតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវបើកគណនីទូទាត់មូលបត្រ នៅប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ការទូទាត់មូលបត្រត្រូវធ្វើឡើង តាមរយៈការផ្ទេរក្នុងបញ្ជី (Book-Entry Transfer) ពីគណនីមូលបត្ររបស់សមាជិក ទៅគណនីទូទាត់មូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្ទេរមូលបត្រដែលទទួលបាននេះ ទៅសមាជិកដែលត្រូវទទួលបានការទូទាត់មូលបត្រ។

## ប្រការ ៩.- ការតម្កល់ធានាការជួញដូរ

មុនអនុវត្តបញ្ជារបស់អតិថិជន សមាជិកត្រូវពិនិត្យឱ្យអតិថិជនដាក់តម្កល់ធានាការជួញដូរ ជាសាច់-ប្រាក់ សម្រាប់ការទិញមូលបត្រ និងជាមូលបត្រសម្រាប់ការលក់មូលបត្រ ឱ្យបានត្រឹមត្រូវតាមកថាខណ្ឌទី ២ នៃប្រការនេះ។

អត្រាអប្បបរមានៃការតម្កល់ធានាការជួញដូរ សម្រាប់ការបញ្ជាទិញ និងការបញ្ជាលក់ មានដូចតទៅ៖

១-ត្រូវមានសាច់ប្រាក់យ៉ាងតិច ១០០% (មួយរយភាគរយ) សម្រាប់ការបញ្ជាទិញមូលបត្រ។

២-ត្រូវមានមូលបត្រដែលត្រូវលក់យ៉ាងតិច ១០០%(មួយរយភាគរយ) សម្រាប់ការបញ្ជាលក់មូលបត្រ។

សមាជិកត្រូវធានាឱ្យបានថាសាច់ប្រាក់ និងមូលបត្រដែលជាទ្រព្យធានាការជួញដូរត្រូវបានរក្សាទុក ឬបង្កកសម្រាប់ការទូទាត់ ឬរហូតដល់ការបញ្ជានោះអស់សុពលភាព។

## ប្រការ ១០.- នីតិវិធីនៃប្រតិបត្តិការផាត់ទាត់និងទូទាត់

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវគណនាចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ចុងក្រោយដោយសមាជិក ដោយធ្វើការបន្សុទ្ធ ឬកាត់កង (Netting) ចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ក្នុងថ្ងៃដូចគ្នា របស់សមាជិកនីមួយៗ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវជូនដំណឹងអំពីព័ត៌មានដូចខាងក្រោមដល់សមាជិកនៅកាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់÷

១-កាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់។

២-បរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬក្នុងនាមអតិថិជន។

៣-ទឹកប្រាក់ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬក្នុងនាមអតិថិជន។

បរិមាណមូលបត្រ និងចំនួនសាច់ប្រាក់ដែលនឹងត្រូវទូទាត់ ត្រូវគណនាស្របតាមវិធីសាស្ត្រនីមួយៗ ដូចខាងក្រោម÷

១-ចំពោះមូលបត្រៈ ត្រូវបានគណនាដោយធ្វើការផាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗ សម្រាប់សមាជិកដែលពាក់ព័ន្ធ។

២-ចំពោះសាច់ប្រាក់ៈ ត្រូវបានគណនាដោយធ្វើការផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សរុបសម្រាប់សមាជិកនីមួយៗដែលពាក់ព័ន្ធ។

សមាជិកត្រូវផ្ទេរមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ ទៅគណនីរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ នៅមុនម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់ (Settlement Date) ហើយប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវធ្វើការទូទាត់មូលបត្រនិងសាច់ប្រាក់បន្តទៅឱ្យសមាជិកដែលត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង ៨:៣០ ព្រឹក នៅថ្ងៃដែលនៅកាលបរិច្ឆេទទូទាត់។

**ប្រការ ១១.- ការប្រគល់ឯកសារទូទាត់**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្តល់នូវឯកសារបង្កាប់ទូទាត់ ដែលរួមមានព័ត៌មានលម្អិតលើមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ជូនដល់សមាជិក ក្រោយការបិទទីផ្សារ តាមរយៈប្រព័ន្ធកុំព្យូទ័រ។

សមាជិកត្រូវពិនិត្យអំពីមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ នៅលើឯកសារបង្កាប់ទូទាត់ និងត្រូវធ្វើការទូទាត់ទៅតាមពេលវេលាកំណត់។

សមាជិកត្រូវប្រគល់ឯកសារទូទាត់ដែលមានព័ត៌មានលម្អិត និងពេលវេលានៃការទូទាត់ជាដើម ជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ក្រោយពីការទូទាត់។

**ប្រការ ១២.- វិធានការវិន័យចំពោះការបរាជ័យនៃការទូទាត់**

ក្នុងករណីដែលសមាជិកណាមួយគ្មានលទ្ធភាពធ្វើការទូទាត់ការជួញដូររបស់ខ្លួន ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រអាចលុបចោលនូវការជួញដូរដែលបានប្រតិបត្តិហើយទាំងស្រុង ឬមួយផ្នែកនៅក្នុង ផ.ម.ក. ឬ/និង ព្យួរការជួញដូររបស់សមាជិកនោះក្នុងរយៈពេលកំណត់មួយ។

ក្នុងករណីដែលមានកង្វះខាតសាច់ប្រាក់ក្នុងការទូទាត់ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រអាចប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីធានាការទូទាត់ លើកលែងតែមានការកំណត់ផ្សេងទៀត។

ក្នុងករណីដែលមានកង្វះខាតមូលបត្រសម្រាប់ទូទាត់ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រត្រូវធ្វើការទូទាត់ ដោយសុំខ្ចីនូវមូលបត្រប្រភេទដូចគ្នាពីសមាជិកផ្សេងទៀត។ ប្រសិនបើការសុំខ្ចី និងការឱ្យខ្ចីមិនអាចធ្វើទៅបាន ការទូទាត់នឹងត្រូវលុបចោល។

ប្រសិនបើ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ មិនអាចរកមធ្យោបាយដើម្បីធ្វើការទូទាត់ដូចមានចែងក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រអាចចាត់វិធានការ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

**ប្រការ ១៣.- អ្នកតំណាងទូទាត់**

សមាជិកនីមួយៗត្រូវតែងតាំង និងចុះឈ្មោះអ្នកតំណាងទូទាត់យ៉ាងហោចណាស់ ០១ (មួយ) រូបដែលត្រូវទទួលការបណ្តុះបណ្តាលពី **ផ.ម.ក.** និងដែលមានសិទ្ធិធ្វើប្រតិបត្តិការទូទាត់ឱ្យសមាជិកនោះ ជាមួយ **ផ.ម.ក.**។

អ្នកតំណាងទូទាត់របស់សមាជិកនោះ អាចជាអ្នកតំណាងទីផ្សារដែលត្រូវបានតែងតាំងដោយសមាជិកស្របតាមវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ **ផ.ម.ក.**។

## ជំពូកទី ៣
## កម្រៃសេវាផាត់ទាត់និងទូទាត់

**ប្រការ ១៤.- កម្រៃសេវាផាត់ទាត់និងទូទាត់**

សមាជិកត្រូវបង់កម្រៃសេវាផាត់ទាត់និងទូទាត់ ជូនប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រតាមអត្រា និងពេលវេលាដូចខាងក្រោម÷

១-កម្រៃសេវាសម្រាប់សេវាផាត់ទាត់និងទូទាត់ ត្រូវយកលើតម្លៃជួញដូរ ដែលត្រូវបានទូទាត់ (ទឹកប្រាក់កម្រៃសេវាត្រូវកាត់ក្បៀសមកត្រឹមមួយខ្ទង់) តាមអត្រា ១០/១០.០០០ (ដប់ភាគមួយម៉ឺន) ឬ 0,១០ % (សូន្យក្បៀសដប់ភាគរយ)។

២-អ្នកបង់កម្រៃសេវាគឺ ក្រុមហ៊ុនមូលបត្រដែលជាសមាជិកនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ។

៣-ពេលវេលានៃការបង់កម្រៃសេវាគឺនៅ ម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

*****